COUNT US IN 2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# ការរក្សាការសម្ងាត់នៃជំរឿន

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ផ្នែកជំរឿនរបស់យើង តាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ www.CountUsIn2020.org/hotline សម្រាប់ព័ត៌មានបន្ថែម។*

ជំរឿនគឺជាការរាប់ចំនួនប្រជាជនទាំងអស់ដែលរស់នៅសហរដ្ឋអាមេរិក។

- ការរាប់ចំនួនប្រជាជននៅក្នុងជំរឿនគឺជះឥទ្ធិពលទៅដល់ចំនួនថវិកាដែលផ្តល់ទៅឱ្យសាលារៀន សេវាថែទាំសុខភាព និងសេវាសំខាន់ៗដទៃទៀតនៅក្នុងតំបន់របស់លោកអ្នក -- កាលណាមានមនុស្សកាន់តែច្រើនត្រូវបានរាប់នៅក្នុងសហគមន៍របស់លោកអ្នក ថវិកាដែលសហគមន៍របស់លោកអ្នកទទួលបានក៏កាន់តែច្រើនទៅតាមនោះដែរ។
- *នៅពេលលោកអ្នកចូលរួមបំពេញជំរឿន លោកអ្នកជួយធ្វើឱ្យប្រាកដថា គ្រួសារនិងសហគមន៍របស់លោកអ្នកទទួលបានចំណែកថវិកា សេវាកម្ម និងការតំណាងផ្នែកនយោបាយដោយស្មើភាព!*

ជំរឿនសួរសំណួរទូទៅមួយចំនួន ដូចជា អាយុ ឈ្មោះ ពូជសាសន៍ និងជាតិសាសន៍របស់មនុស្សម្នាក់ៗដែលរស់នៅក្នុងគ្រួសាររបស់លោកអ្នក។ **ជំរឿនប្រជាជនឆ្នាំ 2020 នឹង *មិន*សួរអំពីស្ថានភាពអន្តោប្រវេសន៍ ឬសញ្ជាតិឡើយ។**

## ចម្លើយជំរឿនរបស់លោកអ្នកនៅក្នុងជំរឿនគឺជាការសម្ងាត់បំផុត។

- មានច្បាប់តឹងរឹងបំផុតសំរាប់រក្សាការពារការសម្ងាត់នៃចម្លើយរបស់លោកអ្នកដែលផ្តល់ជូនក្នុងជំរឿន។
- ការិយាល័យជំរឿនមិនត្រូវបានអនុញ្ញាតឱ្យចែកចាយព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកជាមួយជនណាម្នាក់ឡើយ រួមទាំង ទីភ្នាក់ងារអនុវត្តច្បាប់អន្តោប្រវេសន៍និងគយ (ICE) នគរបាល ឬទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត។
- ការិយាល័យជំរឿនអាចប្រើចម្លើយរបស់លោកអ្នកដើម្បីតែបង្កើតព័ត៌មានទូទៅអំពីប្រជាជនតែប៉ុណ្ណោះ ដូចជា ចំនួនមនុស្សដែលរស់នៅក្នុងទីក្រុងរបស់លោកអ្នក និងស្ថិតិអំពីអាយុ ភេទ និងពូជសាសន៍ប៉ុណ្ណោះ។ ការិយាល័យជំរឿនមិនអាចចែករំលែកព័ត៌មានរបស់លោកអ្នកជាលក្ខណៈបុគ្គលបានឡើយ។

ច្បាប់តម្រូវឱ្យមនុស្សគ្រប់រូបបំពេញជំរឿនដោយពេញលេញ និងឆ្លើយសំណួរទាំងអស់ដោយស្មោះត្រង់។ សូមកុំកុហក់នៅក្នុងជំរឿនឱ្យសោះ។

ទម្រង់បែបបទជំរឿនរបស់លោកអ្នកនឹងនៅតែត្រូវបានរាប់បញ្ចូល បើទោះបីជាលោកអ្នករំលងមួយឬពីរសំណួរក៏ដោយ ដរាបណាលោកអ្នកផ្តល់ឈ្មោះ និងអាសយដ្ឋានរបស់លោកអ្នក។ ប្រសិនបើលោកអ្នករំលងសំណួរ ឬមិនបំពេញជំរឿនទាល់តែសោះ ការិយាល័យជំរឿនប្រហែលជានឹងទាក់ទងមកលោកអ្នកដើម្បីសួររកព័ត៌មានដែលមិនបានបំពេញតាមរយៈទូរស័ព្ទ ឬដោយបញ្ជូនបុគ្គលិកការិយាល័យជំរឿនទៅដល់ផ្ទះរបស់លោកអ្នក។ ប្រសិនបើលោកអ្នករំលងសំណួរកាន់តែតិច ការិយាល័យជំរឿនប្រជាជននឹងមិនទំនងជាទាក់ទងមកលោកអ្នកឡើយ។

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ www.CountUsIn2020.org/resources។*